**អភិបូជាបុណ្យសពលោកឪពុក តូនី វីនដ្រាមីន**

**ព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច**

**ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១**

**"គំរូរបស់លោកឪពុក តូនី វីនដ្រាមីន"**

បងប្អូនជាទីស្រឡាញ់
នៅថ្ងៃនេះ យើងថ្វាយអភិបូជាបុណ្យសពលោកឪពុក តូន វីនដ្រាមីន នៅព្រះវិហារសន្តយ៉ូសែប ផ្សារតូច។ យើងបានធ្វើម៉ោង ៣.០០នាទីរសៀល ដើម្បីឱ្យក្រុមគ្រួសារក៏ដូចជាមិត្តភក្តរបស់លោកឪពុកនៅប្រទេសអ៊ីតាលីបានចូលរួមពីចម្ងាយ (នៅប្រទេសអ៊ីតាលីត្រូវនឹងម៉ោង ៩.០០ព្រឹក) ដូច្នេះជាពេលវេលាមួយដើម្បីភ្ជាប់ជាមួយបងប្អូនគាត់។

លោកឪពុកជាទីស្រឡាញ់ ក្រុមគ្រួសារ បងប្អូន មិត្តភក្តរបស់លោកឪពុកនៅប្រទេសអ៊ីតាលី បងប្អូនជាទីស្រឡាញ់នៅប្រទេសកម្ពុជា ដែលបានធ្វើការជាមួយ ដែលបានស្គាល់លោកឪពុក តូនី ដែលភ្ជាប់ជាមួយលោកឪពុកជាគ្រូគង្វាល ដែលមានចិត្តសប្បុរសដូចព្រះជាម្ចាស់។

នៅថ្ងៃនេះ ជាពិសេសខ្ញុំសូមអធិដ្ឋាន និងនឹករលឹកដល់ក្រុមបងស្រីនៃអ្នកម្ដាយតេរេសា ដែលបានមកដល់ប្រទេសកម្ពុជាក្នុងឆ្នាំ១៩៩១ ដោយសារវត្តមានរបស់លោកឪពុក តូនី។ តាមពិតប្រសិនបើបងស្រីឥតមានលោកឪពុកក៏មកមិនបាន ព្រោះថាបងស្រីត្រូវការមានអភិបូជាប្រចាំថ្ងៃ។

ខ្ញុំនឹករលឹកដល់បងស្រី ជាពិសេសក្រុមគ្រួសារបងស្រីសាឡេស៊ាន ក៏ដូចជាបងស្រីកាម៉ែល ដែលបានទទួលអគ្គសញ្ញាព្រះកាយព្រះគ្រីស្ត អគ្គសញ្ញាលើកលែងទោស ដោយសាលោកឪពុក តូនី បានយកចិត្តទុកដាក់រហូតដល់ពេលវេលាចុងក្រោយរបស់គាត់ មុនពេលលោកចូលមន្ទីរពេទ្យក៏លោកបានទៅថ្វាយអភិបូជាឱ្យបងស្រីយ៉ាងច្រើន។

នៅពេលនេះ ខ្ញុំអធិដ្ឋាននិងនឹករលឹកដល់បងប្អូនមួយចំនួនយ៉ាងធំ ដែលបានធ្វើការជាមួយលោកឪពុក តូនី នៅក្នុងអង្គការមនុស្សលោកថ្មី។ ណែនាំឱ្យមនុស្សយ៉ាងច្រើន ជាពិសេសបងប្អូនតូចតាចដែលសង្គមពូកែភ្លេច រកឃើញសេចក្តីសង្ឃឹមដ៏ពិតប្រាកដ។

នៅពេលនេះ ខ្ញុំអធិដ្ឋាននិងនឹករលឹកដល់ព្រះសហគមន៍ដែលលោកឪពុក តូនី បានបម្រើ ជាពិសេសនៅពេលគាត់ចូលនិវត្តន៍បម្រើដោយយកចិត្តទុកដាក់ ដោយចិត្តអត់ធ្មត់ ដោយសេចក្តីស្រឡាញ់ នៅព្រះវិហារពោធិ៍ចិនតុង។

ថ្ងៃនេះខ្ញុំអធិដ្ឋានពិសេស សម្រាប់ព្រះសហគមន៍នៅអំពៅព្រៃដែលបានជួបព្រះយេស៊ូគ្រីស្តដែលបានរីកចម្រើននៅក្នុងជំនឿដោយសារលោកឪពុក តូនី។ ខ្ញុំសូមនិយាយដល់ព្រះសហគមន៍ថា "**កុំព្រួយបារម្ភលោកឪពុក តូនី អធិដ្ឋាន ខ្ញុំក៏អធិដ្ឋានដែរដើម្បីឱ្យយើងបន្តយកចិត្តទុកដាក់តស៊ូសម្រាប់ថ្ងៃនេះនិងថ្ងៃស្អែក**"។

ថ្ងៃនេះ ជាពិសេសខ្ញុំសូមអធិដ្ឋានសម្រាប់លោកឪពុកក្រុមភីមេ PIME ដោយបង្ហាញមិត្តភាពភាតរភាព។ ក្រុមលោកឪពុកដែលបានបាត់លោកតា បាត់មិត្តភក្ត និងដែលបានយកចិត្តទុកដាក់ជាមួយលោកឪពុក តូនី រហូតដល់ដង្ហើមចុងក្រោយ ដោយថែរក្សាលោកឪពុក តូនី ដូចជាកូន ដូចជាឪពុកបង្កើត សូមព្រះជាម្ចាស់ប្រទានព្រះពរដល់លោកឪពុកទាំងអស់។

បងប្អូនជាទីស្រឡាញ់ នៅពេលរសៀលនេះយើងថ្វាយអភិបូជាបុណ្យសពលោកឪពុក តូនី ជាពេលវេលាមួយ ដែលយើងអធិដ្ឋានអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរបស់លោកឪពុក ដែលលោកឪពុកបានធ្វើជូនដល់ព្រះជាម្ចាស់ និងមនុស្សតូចតាចនៅប្រទេសបង់ក្លាដេស និងប្រទេសកម្ពុជា។

ថ្ងៃនេះ ជាពេលវេលាដើម្បីអរព្រះគុណព្រះជាម្ចាស់សម្រាប់ជីវិតរបស់លោកឪពុក និងដើម្បីបង្ហាញអំពីជំនឿដែលជាជំនឿរបស់លោកឪពុកដែរ អំពីសេចក្តីសង្ឃឹមដែលជាសេចក្តីសង្ឃឹមរបស់លោកឪពុកទៅលើព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ។

នៅពេលនេះ លោកឪពុក តូនី ដែលបានតស៊ូ ដែលបានយកចិត្តទុកដាក់អស់មួយជីវិតភ្ជាប់ជាមួយព្រះជាម្ចាស់នៅស្ថានបរមសុខ។ ព្រះជាម្ចាស់ដែលលោកឪពុកបានបម្រើ និងស្រឡាញ់ នៅ

ក្នុងជីវិតដែលមានផលផ្លែយ៉ាងច្រើន និងនៅក្នុងជីវិតដែលលោកឪពុកបានដាក់ខ្លួនជានិច្ច ដើម្បីបម្រើបងប្អូនឯទៀតៗ។

ខ្ញុំសូមអធិដ្ឋាន ដើម្បីឱ្យគំរូនៃជីវិតរបស់លោកឪពុក តូនី ណែនាំឱ្យយើងមានកម្លាំងកាយកម្លាំងចិត្ត ដើម្បីបន្តធ្វើដំណើរលើផែនដីនេះ។ ពិតមែន លោកឪពុក តូនី បានធ្វើការអស្ចារ្យយ៉ាងច្រើនលើផែនដីនេះ ពោរពេញដោយសេចក្តីស្រឡាញ់យ៉ាងធំធេង។

នៅពេលនេះខ្ញុំជឿថាលោកឪពុក តូនី ដែលធ្លាប់ជួបអ្នកម្តាយតេរេសាមួយភ្លែតនៅប្រទេសកម្ពុជា នៅពេលនេះលោកឪពុកនឹងភ្ជាប់ជាមួយសន្តីតេរេសានៅឯស្ថានបរមសុខអស់កល្បជានិច្ច។ នៅពេលនេះ ទាំងអ្នកម្តាយតេរេសា ទាំងលោកឪពុក តូនី និយាយដល់យើងថា "**ពិតមែនមនុស្សទាំងអស់មិនអាចធ្វើការអស្ចារ្យនៅលើផែនដីនេះ ប៉ុន្តែយើងទាំងអស់គ្នាយើងអាចធ្វើការងារ ឬស្នាដៃដ៏តូចតាចដែលពោរពេញដោយសេចក្តីស្រឡាញ់ដ៏ធំធេង**"។ យើងអធិដ្ឋានផ្ញើវិញ្ញាណក្ខន្ធរបស់លោកឪពុក តូនី វីនដ្រាមីន ទៅលើព្រះជាម្ចាស់។ អាម៉ែន៕

+ លោកអភិបាល អូលីវីយេ ផ្មឹតហាស្លេ
អភិបាលព្រះសហគមន៍កាតូលិកកម្ពុជា
ភូមិភាគភ្នំពេញ